**របាយការណ៍សង្ខេបនៃកិច្ចប្រជុំ**

**រវាង ឯកឧត្តម តែង គន្ធី និង អ្នកស្រី ឃ្លែរ ស្តុក ប្រធានអង្គការ PSK**

នៅព្រឹកថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៤ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ **ឯកឧត្តម វេជ្ជបណ្ឌិត តែង គន្ធី** អគ្គលេខាធិការ បានជួបប្រជុំជាមួយ អ្នកស្រី ***ឃ្លែរ ស្តុក*** (Claire Stokes) ប្រធានថ្មីរបស់ អង្គការបម្រើសេវាសុខភាពកម្ពុជា(PSK) ។ កិច្ចប្រជុំមានគោលបំណងសំខាន់ដើម្បីធ្វើការណែនាំ និងពង្រឹងការទំនាក់ទំនង កិច្ចសហប្រតិបត្តិការរវាងស្ថាប័នអាជ្ញាធរជាតិ ជាមួយ អង្គការសង្គមស៊ីវិលដែលធ្វើការងារប្រយុទ្ធជាមួយមេរោគអេដស៍។



ជាមួយនឹងការថ្លែងអំណរគុណដល់អង្គការបម្រើសេវាសុខភាពកម្ពុជា(PSK)ដែលបានចូលរួមចំណែកយ៉ាងសកម្មក្នុងការទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជាកន្លងមក ក្នុងនោះដែរ **ឯកឧត្តមអគ្គលេខាធិការ** បានលើកស្នើឡើងនូវចំណុចសំខាន់ៗដើម្បីអោយមានការចូលរួម និងគាំទ្របន្ថែមទៀតដូចជា:

- ពង្រឹងកិច្ចសហការណ៍ និងការអនុវត្តការងារបន្ថែមទៀតផ្អែកលើគោលនយោបាយនឹងយុទ្ធសាស្រ្តជាតិប្រយុទ្ធជំងឺអេដស៍។
- បន្តការជួយផ្តល់ស្រោមអនាម័យដើម្បីចូលរួមក្នុងកម្មវិធីផ្សេងៗ ដូចជាបុណ្យអុំទូក ទិវាប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ ទិវានៃក្តីស្រឡាញ់ ទិវាសិទ្ធិនារី...
- បន្តសហការណ៍ផ្តល់វគ្គបណ្តុះបណ្តាលពីចំណេះដឹង និងជំនាញចាំបាច់ដូចជា ភាពជាអ្នកដឹកនាំ សុខភាពផ្លូវភេទ... និងកសាងសមត្ថភាពដល់យុវជន និងសហ -

គមន៍ងាយរងគ្រោះ ចូលរួមផ្សព្វផ្សាយស្តីពីការបង្ការ និងការពារមេរោគអេដស៍ ជាមួយប្រព័ន្ធផ្សព្វផ្សាយ។

- ស្នើឱ្យអង្គការបម្រើសេវាសុខភាពកម្ពុជា(PSK)ជួយគាំទ្រដល់បណ្ណាល័យ ឬមជ្ឈ - មណ្ឌលពត៌មាន ដែលជាកន្លែងផ្តល់ពត៌មានចាំបាច់បន្ថែមដល់ប្រជាពលរដ្ឋទូទៅ ជាពិសេស(សម្រាប់យុវជន និងក្រុមងាយរងគ្រោះ)
- ចូលរួមគាំទ្រដល់ដំណើរការពិនិត្យឡើងវិញពី NSPIV ឆ្នាំ ២០១៦ - ២០២០

ក្នុងការឆ្លើយតបទៅនឹងសំណើរ និងតម្រូវការរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ អ្នកស្រីប្រធានអង្គការ PSK សន្យាថា នឹងពិនិត្យមើលលទ្ធភាពរបស់អង្គការ ដើម្បីចូលរួមចំណែកគាំទ្រដល់ការស្នើសុំទាំងអស់នេះ ជាពិសេសលើការពិនិត្យឡើងវិញផែនការយុទ្ធសាស្រ្តជាតិ។ ក្នុងនោះដែរ អ្នកស្រីបានស្នើសុំមកខាងអាជ្ញាធរជាតិ ឱ្យជួយពិនិត្យមើល ឃ្លីបវីដេអូ ខ្លី (Short Video Clip) ដែលអង្គការ បានរៀបចំឡើង ដើម្បីផ្សព្វផ្សាយពីស្រោមអនាម័យ។